អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## លោក អាង ឧត្តម និងលោក MICHAEL G. KARNAVAS បានទទួលការតែងតាំងជាមេធាវីការពារក្តីតំណាងជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង ០០៣

ផ្នែកគាំពារការការពារក្តី (DSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានតែងតាំងលោក អាង ឧត្តម ជាសហមេធាវីកម្ពុជា និងលោក Michael G. Karnavas ជាសហមេធាវីបរទេស ដើម្បីតំណាងជនសង្ស័យមួយរូបដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរនេះ គឺជាផ្នែកមួយនៃសំណុំឯកសារក្នុងសំណុំរឿង ០០៣។

អត្តសញ្ញាណរបស់ជនសង្ស័យ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរនេះ នៅតែត្រូវបានរក្សាទុកជាសម្ងាត់។

លោក អាង ឧត្តម និងលោក Michael G. Karnavas គឺជាមេធាវីការពារក្តីដ៏មានបទពិសោធន៍ក្នុងរឿងក្តីព្រហ្មទណ្ឌ និងកំពុងបំពេញការងារនៅ អ.វ.ត.ក នាពេលបច្ចុប្បន្ន។ នៅ អ.វ.ត.ក ពួកគាត់តំណាងលោក អៀង សារី ដែលជាជនជាប់ចោទមួយរូបក្នុងសំណុំរឿង ០០២។

នេះគឺជាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រនៃ អ.វ.ត.ក ដែលផ្នែកគាំពារការការពារក្តីបានតែងតាំងមេធាវីដើម្បីតំណាងជនសង្ស័យ ឬជនជាប់ចោទជាច្រើនរូបក្នុងពេលដំណាលគ្នា។ នៅក្នុងការតែងតាំងនេះ ផ្នែកគាំពារការការពារក្តីបានពិនិត្យពិចារណាទៅលើជម្រើសរបស់ជនសង្ស័យ បទពិសោធន៍ទូទៅរបស់មេធាវីក្នុងវិស័យច្បាប់មនុស្សធម៌ និងឧក្រិដ្ឋកម្មអន្តរជាតិ, កម្រិតនៃការយល់ដឹងរបស់ពួកគាត់អំពីវិធានជាមូលដ្ឋាន, ទម្លាប់អនុវត្តន៍ និងនីតិវិធីនៅ

អ.វ.ត.ក, ចំណេះដឹងរបស់ពួកគាត់អំពីបរិបទប្រវត្តិសាស្ត្រ និងនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងលិខិតបដិសេធអំពីទំនាស់ផលប្រយោជន៍ទាំងអស់ជាធរមាន។ អង្គភាពគាំពារការការពារក្តីក៏បានពិនិត្យពិចារណាអំពីអំណះអំណាងរបស់ជនសង្ស័យអំពីភាពក្រីក្រផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោកស្រី យូកូ មេដា
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ៖ +៨៥៥ (0)១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦១ ៦៣៩
លេខភ្ជាប់បន្ត៖ ៦១៣៩
សារអេឡិចត្រូនិក៖ maeday@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh



Original EN: 00868714-00868714